កិច្ចការ២១:១-២៦

# ជំពូក ២១

***ណាទចនា*** *សាវ័កប៉ុលទៅដល់ទីក្រុងយេរូសាឡិម រួចហើយគេចាប់ខ្លួនលោកនៅទីនោះ*

*សាវ័កប៉ុលនៅទីក្រុងទីរ៉ុស*

*សាវ័កប៉ុលនៅទីក្រុងសេសារា*

*សាវ័កប៉ុលនៅទីក្រុងយេរូសាឡិម*

*គេចាប់ខ្លួនសាវ័កប៉ុលនៅទីក្រុងយេរូសាឡិម*

*គេដាក់ច្រវ៉ាក់សាវ័កប៉ុល*

## សាវ័កប៉ុលនៅដល់ទីក្រុងយេរូសាឡិម ...គេចាប់ខ្លួនលោកនៅទីនោះ

សាវ័កប៉ុល បានធ្វើដំណើរបំពេញបេសកកម្មបីលើកចប់សព្វគ្រប់ហើយ។ បេសកកម្មទាំងបីលើក រាប់ថាជាជោគជ័យយ៉ាងត្រចះត្រចង់សម្រាប់លោក និងគូកនរបស់លោកក្នុងការផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ឥឡូវ លោកបានធ្វើដំណើរចូលមកទីក្រុងយេរូសាឡិម ប៉ុន្តែ មុននឹងលោកអញ្ជើញមកដល់ទីក្រុង

យេរូសាឡិម មានគេជម្រាបលោកថា គេគុំចាប់លោកនៅទីនោះ។ លោកជ្រាបច្បាស់ថា ការអញ្ជើញត្រឡប់មកទីក្រុងយេរូសាឡិមវិញ ច្បាស់ជាមានគ្រោះថ្នាក់រង់ចាំលោកនៅទីនោះជាពិតប្រាកដ។

## សាវ័កប៉ុលនៅទីក្រុងទីរ៉ុស

**[1]កាលយើងបានឃ្លាតចេញផុតពីគេទៅហើយ នោះក៏បើកក្តោងដំរង់ទៅឯកោះកូស ហើយថ្ងៃក្រោយបានដល់កោះរ៉ូដូស រួចពីនោះទៅដល់ក្រុងប៉ាតារ៉ា [2]កាលឃើញសំពៅ១ មានដំណើរទៅឯស្រុកភេនីស នោះយើងក៏ចុះតាមសំពៅនោះចេញទៅទៀត (កិច្ចការ២១:១-២)។**

បន្ទាប់ពីសាវ័កប៉ុលចុះសំពៅនៅទីក្រុងមីលេត លោកធ្វើដំណើរឆ្ពោះមកទីក្រុងប៉ាតារ៉ា គឺជាក្រុងមួយដែលស្ថិតនៅម្តុំខាងត្បូង លើឆ្នេរសមុទ្រទ្វីបអាស៊ី ភាគខាងលិច។ ក្រោយពីរកសំពៅដូរនៅទីក្រុងនោះបានហើយ លោកធ្វើដំណើរចុះទៅទីក្រុងទីរ៉ុស។ ទីក្រុងនេះស្ថិតនៅខាងជើងទីក្រុងសេសារា តាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ។ ទីក្រុងនេះ ពីដើមហៅថា ស្រុកភេនីស។ សព្វថ្ងៃគឺជាប្រទេសល្បាណូន។

**ដល់បានឃើញកោះគីប្រុសហើយ នោះបានបើកបង្ហួសទៅខាងឆ្វេង រួចទៅដល់ស្រុកស៊ីរី ចូលចតនៅត្រង់ក្រុងទីរ៉ុស ដ្បិតសំពៅត្រូវបើទំនិញនៅទីនោះ (កិច្ចការ២១:៣)។**

នៅពេលដែលលោកធ្វើដំណើរតាមសំពៅ លោកមើលឃើញកោះគីប្រុស។ លោកមិនបានចុះនៅទីនោះទេ គឺលោកធ្វើដំណើរឆ្ពោះទៅទីក្រុងទីរ៉ុសវិញ។ ទីក្រុងទីរ៉ុស គឺជាទីក្រុងពាណិជ្ជកម្មយ៉ាងសំខាន់នៅក្នុងតំបន់នោះ។

**លុះកាលរកឃើញពួកសិស្សហើយ នោះក៏ស្នាក់នៅទីនោះ៧ថ្ងៃ ហើយគេឃាត់ប៉ុលដោយនូវព្រះវិញ្ញាណ មិនឱ្យគាត់ឡើងទៅឯក្រុងយេរូសាឡិមឡើយ (កិច្ចការ២១:៤)។**

ខខាងលើនេះ គឺជាខដែលគ្រូបង្ហាត់បង្រៀនព្រះបន្ទូលមិនយល់ស្របជាមួយនឹងគ្នាទាំងស្រុងទេ។ គ្រូបកស្រាយគម្ពីរខ្លះបន្ទោសសាវ័កប៉ុលថា បើលោកដឹងថាព្រះវិញ្ញាណបរិសុទ្ធមិនចង់អោយលោកចុះទៅទីក្រុងយេរូសាឡិមហើយ ហេតុអ្វីបានជាលោកចចេសធ្វើខុសជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះ។ មានគ្រីស្ទបរិស័ទជាច្រើន បានជម្រាបសាវ័កប៉ុលថា លោកមិនគួរធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិមទេ ដ្បិតនៅទីនោះលោកច្បាស់ជាជួបជាមួយនឹងគ្រោះថ្នាក់ជាមិនខាន។ បើតាមខ្ញុំយល់វិញ

ព្រះវិញ្ញាណបរិសុទ្ធនៃព្រះមិនដែលធ្វើអ្វីទាស់ទទឹងជាមួយនឹងអង្គទ្រង់ផ្ទាល់ទេ។ សាវ័កប៉ុលធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិម ថ្វីដ្បិតលោកជ្រាបថា ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបានបើកសម្តែងអោយអ្នកដទៃទៀតដឹងថា លោកត្រូវទទួលគ្រោះថ្នាក់នៅទីនោះ។ សាវ័កប៉ុលមិនបានធ្វើអ្វីទាស់ទទឹងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ស្តីអំពីដំណើរនេះទេ។ ព្រះវិញ្ញាណបរិសុទ្ធ គ្រាន់តែបើកសម្តែងអោយអ្នកដទៃទៀតដឹងថា សាវ័កប៉ុលពិតជាមានគ្រោះថ្នាក់ជាមិនខាន។ ប៉ុន្តែ ទោះជាលោកជ្រាបច្បាស់អំពីដំណើរនោះក៏ដោយ សាវ័កប៉ុលនៅតែមានចិត្តចុះទៅទីក្រុងយេរូសាឡិមដដែល ដើម្បីទទួលទុក្ខលំបាក ដែលព្រះជាម្ចាស់ត្រៀមសម្រាប់លោក។ សាវ័កប៉ុលត្រៀមខ្លួនទទួលធ្វើជាយញ្ញបូជាដោយចិត្តសុទ្ធាជ្រះថ្លា។ លោកព្រមព្រៀងប្រគល់ជីវិតរបស់លោកថ្វាយដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ខ្ញុំយល់ថា សាវ័កប៉ុលមិនបានទាស់ទទឹងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គទេ គឺលោកព្រមចុះចូលជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះវិញ។

ឥឡូវ សូមយើងពិចារណាមើលអំពីមូលហេតុដែលខ្ញុំជឿថា សាវ័កប៉ុលមិនបានធ្វើខុសជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះ ក្នុងការធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិម។ នៅពេលដែលលោកធ្វើដំណើរបេសកកម្មលើកទីបី លោកទទួលបញ្ញើជាច្រើន ដែលក្រុមជំនុំសាសន៍ដទៃលើកជាដង្វាយផ្ញើតាមលោក ទៅជួយសម្រាលទុក្ខពួកបរិសុទ្ធដែលនៅក្នុងក្រុងយេរូសាឡិម។ ក្នុងនាមលោកអ្នកទទួលបញ្ញើផ្ទាល់របស់ក្រុមជំនុំសាសន៍ដទៃនៅទ្វីបអាស៊ីចុងខាងលិច និងដង្វាយមកពីពួកជំនុំនៅទ្វីប

អ៊ីរ៉ុប លោកចង់យកជង្វាយទាំងនោះ ទៅប្រគល់អោយអ្នកចាស់ទុំនៅទីក្រុងយេរូសាឡិមដោយផ្ទាល់ដៃលោក។ រឿងនេះ លោកមិនចាំបាច់ធ្វើខ្លួនឯងទេ តែដោយសារលោកជាអ្នកទទួលបន្ទុកផ្ទាល់ពីក្រុមជំនុំដទៃៗទៀត លោកចាំបាច់ត្រូវធ្វើការនេះខ្លួនឯង។ ដូច្នេះ ហើយបានជាលោកចាំបាច់ត្រូវចុះទៅទីក្រុងយេរូសាឡិម។ ឯការចុះទៅទីក្រុងយេរូសាឡិមនេះ មិនមែនជាការទាស់ទទឹងជាមួយនឹងព្រះហឫទ័យបំណងរបស់ព្រះទេ។

ខ្ញុំនៅមានមូលហេតុមួយទៀត ដែលជឿថា សាវ័កប៉ុលមិនបានធ្វើអ្វីខុសនឹងបំណងព្រះហឫទ័យរបស់ព្រះទេ។ រឿងនេះ យើងឃើញនៅក្នុងសំបុត្រដែលលោកសរសេរទៅកាន់ពួកជំនុំនៅទីក្រុងភីលីព។ នៅពេលដែលលោកជាប់ពន្ធនាគារនៅក្នុងទីក្រុងរ៉ូម លោកសរសេរទៅកាន់ពួកជំនុំទីក្រុងភីលីពសម្ដែងអំពីទឹកចិត្តស្រឡាញ់ និងទឹកចិត្តស្និទ្ធស្នាលរបស់លោកចំពោះពួកជំនុំនោះ។ លោកសរសេរថា "បងប្អូនអើយ ខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹងថា ការទាំងប៉ុន្មានដែលកើតឡើងដល់ខ្ញុំ នោះបានប្រែទៅជាចំរើនដល់ដំណឹងល្អវិញ" (ភីលីព១:១២)។ ធម្មតាបើអ្នកដឹកនាំចលនាណាមួយជាប់គុក ចលនារបស់គេត្រូវបែកខ្ញែកអស់ជាមិនខាន។ ប៉ុន្តែដោយឡែកករណីរបស់សាវ័កប៉ុល ការជាប់គុករបស់លោក មិនមែនជាឧបសគ្គសម្រាប់ដំណឹងល្អទេ។ ផ្ទុយទៅវិញ លោកព្រមរងទុក្ខដោយគេចាប់លោកដាក់ពន្ធនាគារ ដើម្បីអោយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ រឹតតែរីកចម្រើនឡើងថែមទៀត។ សាវ័កប៉ុលមិនបានធ្វើផ្ទុយនឹងបំណងព្រះហឫទ័យរបស់ព្រះ ក្នុងការចុះទៅទីក្រុងយេរូសាឡិមទេ។

ខ្ញុំនៅមានមូលហេតុមួយផ្សេងទៀត ដែលថាសាវ័កប៉ុលចុះទៅទីក្រុងយេរូសាឡិម តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅពេលលោកខ្វាក់ភ្នែក លោកស្នាក់នៅទីក្រុងដាម៉ាសចំនួនបីថ្ងៃ។ ព្រះជាម្ចាស់បើកសម្តែងអោយអាន្នានាសដឹងពីរឿងរបស់សាវ័កប៉ុល។ ព្រះអម្ចាស់ចង់អោយសាវ័កប៉ុលទទួលរងទុក្ខសម្រាប់ព្រះនាមរបស់ព្រះអង្គ។ ព្រះអង្គមានបន្ទូលទៅកាន់លោកអាន្នានាសថា "...ចូរទៅចុះ ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ សំរាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ នឹងពួកស្តេច ហើយនឹងពួកកូនចៅសាសន៍អ៊ីស្រាអែលផង ដ្បិតខ្ញុំនឹងបង្ហាញឱ្យគាត់ដឹងជាត្រូវរងទុក្ខលំបាកទាំងអម្បាលម៉ានដោយព្រោះឈ្មោះខ្ញុំ" (កិច្ចការ៩:១៥-១៦)។ ក្នុងពេលដែលយើងកំពុងសិក្សាគម្ពីរកិច្ចការនោះ សាវ័កប៉ុលមិនទាន់មានឱកាសនាំដំណឹងល្អទៅផ្សព្វផ្សាយអោយពួកស្តេច ហើយនិងពួកនាហ្មឺនមន្ត្រីទេ។ ប៉ុន្តែ មិនយូរប៉ុន្មានព្រះជាម្ចាស់នឹងប្រើលោក ដើម្បីអោយនាំដំណឹងល្អដល់ពួកស្តេច ហើយនិងពួកនាហ្មឺនមន្ត្រី។ នៅក្នុងជំពូកបន្ទាប់ទៅទៀត សាវ័កប៉ុលឡើងទៅជួបស្តេច ដើម្បីផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវ។ លោកបានធ្វើទីបន្ទាល់ថ្វាយស្តេចអ័គ្រីប៉ា។ បើតាមការសន្និដ្ឋាន លោកប្រហែលជាបានធ្វើទីបន្ទាល់ថ្វាយដល់ស្តេចនេរ៉ូ ដែលគ្រប់គ្រងចក្រភពរ៉ូមទាំងមូលផង។ សាវ័កប៉ុលពិតជាបានផ្សព្វផ្សាយដំណឹងល្អដល់ដំណាក់មហាក្សត្រសេសារពិតប្រាកដមែន ដ្បិតលោកជម្រាបដល់ពួកជំនុំនៅទីក្រុងភីលីពថា "ពួកបរិសុទ្ធទាំងអស់គ្នា មានពួកអ្នកនៅដំណាក់សេសារជាដើម ក៏សូមជំរាបសួរមកអ្នករាល់គ្នាដែរ" (ភីលីព៤:២២)។ សំបុត្រដែលលោកសរសេរមកកាន់ពួកជំនុំនៅទីក្រុងភីលីព គឺជា

សំបុត្រដែលលោកសរសេរពេលលោកជាប់ព័ន្ធនាគារនៅក្នុងទីក្រុងរ៉ូម។

ឯមូលហេតុមួយទៀត ដែលខ្ញុំហ៊ានអះអាងថា ការចុះទៅទីក្រុងយេរូសាឡិម ពិតជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះសាវ័កប៉ុល គឺខ្លួនលោកផ្ទាល់បានសរសេរសំបុត្រទៅកាន់សិស្សរបស់លោកឈ្មោះធីម៉ូថេ។ នៅក្នុងសំបុត្រនោះលោកបញ្ជាក់ថា "ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច..." (២ធីម៉ូថេ៤:៧)។ សំបុត្រនេះលោកសរសេរមុនលោកទទួលមរណភាព។ ដូច្នេះ ហេតុការណ៍ដែលលោកធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិម ទោះបីដឹងថា គ្រោះថ្នាក់រង់ចាំលោកនៅទីនោះក៏ដោយ លោកបានធ្វើដំណើរទៅទីនោះ នៅក្នុងព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់។

ចុះយើងគ្រប់គ្នាវិញ តើបានដើរឃ្លាតចាកអំពីបំណងព្រះហឫទ័យរបស់ព្រះនៅក្នុងជីវិតម្ដងម្កាលដែរឬទេ? ខ្ញុំមិនដឹងជាលោកអ្នកយល់ថា លោកអ្នកបានដើរឃ្លាតចាកពីបំណងព្រះហឫទ័យរបស់ព្រះខ្លះដែរ ឬមួយយ៉ាងណានោះទេ។ ចំណែកខ្ញុំវិញ ខ្ញុំហ៊ានសារភាពនៅចំពោះលោកអ្នកបងប្អូនថា ខ្ញុំពិតជាបានដើរឃ្លាតចាកពីព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់ម្ដងម្កាលដែរ។ ខ្ញុំមិនចង់ធ្វើទេ គឺខ្ញុំធ្វើការនោះដោយល្ងង់ខ្លៅ។ ជួនកាលខ្ញុំជាមនុស្សរឹងទទឹងខ្លាំងណាស់ដែរ ប៉ុន្តែអរព្រះគុណដល់ព្រះអង្គដែលទ្រង់មានសេចក្ដីមេត្តាករុណាដល់ខ្ញុំ បានជាទ្រង់ចេះតែគោះតម្រង់ហៅខ្ញុំត្រឡប់មកវិញអោយនៅតែបម្រើព្រះអង្គមកទល់ថ្ងៃនេះ។ ចំណែកសាវ័កប៉ុលវិញ ខ្ញុំមិនជឿថា លោកធ្វើអ្វីខុសពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ។ ការធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិម ដើម្បីទទួលការរងទុក្ខ គឺបំណងព្រះហឫទ័យរបស់ព្រះសម្រាប់រូបលោក។

លោកដឹងច្បាស់លាស់ថា ការធ្វើដំណើរទៅនោះ មិនមែនជារឿងទាស់ទទឹងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធឡើយ។

> **ប៉ុន្តែ ដល់ផុតថ្ងៃទាំងនោះទៅ យើងក៏ចេញធ្វើដំណើរដើរទៀត ឯពួកគេទាំងអស់ ព្រមទាំងប្រពន្ធកូន បានជូនយើងខ្ញុំទៅខាងក្រៅទីក្រុង រួចយើងលុតជង្គង់អធិស្ឋាននៅមាត់ច្រាំង (កិច្ចការ ២១:៥)។**

សាវ័កប៉ុលនិងពួកជំនុំ នាំគ្នាលុតជង្គង់អធិស្ឋាននៅក្បែរមាត់ច្រាំង។ ខ្ញុំជឿថាកិរិយាអធិស្ឋានដោយលុតជង្គង់នៅចំពោះព្រះ ជាកិរិយាដែលសមរម្យជាទីបំផុត។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ គ្រីស្ទបរិទ័សមិនមានរបៀបអធិស្ឋានណាមួយ ដែលធ្វើអោយយើងបានជិតព្រះជាងរបៀបមួយនោះទៀតទេ។ ការអធិស្ឋានយើងអាចធ្វើដោយវិធីណាក៏បាន ប៉ុន្តែវិធីដែលសមរម្យនៅចំពោះព្រះនេត្រព្រះដ៏មានព្រះជន្មរស់ គឺត្រូវអធិស្ឋានដោយលុតជង្គង់។

> **៦ កាលបានលាគ្នារួចជាស្រេច នោះយើងក៏ចុះសំពៅទៅ ហើយពួកគេត្រឡប់ទៅផ្ទះវិញ ៧ លុះសំរេចដំណើរពីក្រុងទីរ៉ុស ទៅដល់ផ្ទលេមេហើយ នោះក៏ទៅជំរាបសួរដល់ពួកជំនុំ ហើយបានសំចត**

**នៅជាមួយនឹងគេអស់១ថ្ងៃ (កិច្ចការ២១:៦-៧)។**

កំពុងដែលលោកធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិម លោកមិនបានឈប់យូរនៅតាមក្រុងនានាដែលមានពួកជំនុំទេ។ នៅតាមទីកន្លែងនីមួយៗ ដែលលោកចុះសំចត មានពួកជំនុំមកទទួលលោកដោយរាក់ទាក់ជាទីបំផុត។ ខ្ញុំជឿថា នៅក្នុងសតវត្សរ៍ទីមួយ អ្នកជឿដែលរស់នៅក្នុងចក្រភពរ៉ូម មានប្រមាណរាប់លាននាក់រួចទៅហើយ។

## សាវ័កប៉ុលនៅទីក្រុងសេសារា

**ដល់ថ្ងៃស្អែកឡើង ប៉ុលនឹងពួកគាត់បានចេញទៅឯសេសារា ក៏ចូលទៅក្នុងផ្ទះរបស់ភីលីព ជាអ្នកផ្សាយដំណឹងល្អម្នាក់ក្នុងពួកទាំង៧នាក់នោះ ហើយស្នាក់នៅនឹងគាត់ (កិច្ចការ២១:៨)។**

សាវ័កប៉ុលធ្វើដំណើរពីទីក្រុងមួយទៅទីក្រុងមួយ ដោយថ្មើរជើង។ លោកចាំបាច់ត្រូវធ្វើដំណើរបែបនោះ ពីព្រោះលោកចង់ឈប់សួរសុខទុក្ខពួកជំនុំនៅទីក្រុងគ្រប់ទីកន្លែងដែលលោកបានផ្សព្វផ្សាយដំណឹងល្អអោយដល់គេ។ ម្យ៉ាងវិញទៀត លោកឃើញ

មានទ្វារបើកចំហសម្រាប់ដំណឹងល្អ បានជាលោកចាំបាច់ត្រូវធ្វើដំណើរផ្លាល់ច្រើរជើងវិញ។

តើការដើរសួរសុខទុក្ខពួកជំនុំមានប្រយោជន៍អ្វីខ្លះ សម្រាប់យើងនិងសម្រាប់ពួកជំនុំ? សម្រាប់យើង ការឃើញមានពួកជំនុំតាំងនៅគ្រប់ទីកន្លែង ជាការលើកទឹកចិត្តដល់យើងយ៉ាងខ្លាំងភ្លា។ ម្យ៉ាងវិញទៀត ការឃើញពួកជំនុំថ្វាយបង្គំព្រះអង្គ តាមជីវភាពរស់នៅរបស់គេ ទោះគេក្រីក្រ តែគេស្រឡាញ់ដល់ព្រះអង្គ ជាការលើកទឹកចិត្តដល់យើង ពិសេសនៅចុងកាត់មាត់ញក។ ម្យ៉ាងទៀត ការធ្វើដំណើរតាមពួកជំនុំធ្វើអោយយើងមានទំនុកចិត្តថា ពួកជំនុំមិនមែនមានតែមួយកន្លែងទេ។ នៅពេលលោកអេលីយ៉ាអស់ទឹកចិត្ត លោករត់ទៅពួននៅក្នុងព្រៃជ្រៅ ហើយទូលព្រះជាម្ចាស់ថា "នៅក្នុងចំណោមអ្នកជឿព្រះ គ្មានអ្នកណាទៀតទេ មានតែខ្ញុំម្នាក់ដែលរត់មកពួនក្នុងព្រៃនេះតែប៉ុណ្ណោះ"។ ការដើរសួរសុខទុក្ខពួកជំនុំ លើកទឹកចិត្តដល់ពួកជំនុំដែលនៅតាមមូលដ្ឋានផងដែរ។ ពួកជំនុំនៅតាមមូលដ្ឋាន កម្របានជួបអ្នកដឹកនាំក្រុមជំនុំគ្រីស្ទបរិស័ទពីទីកន្លែងផ្សេងៗណាស់។ នៅពេលណាដែលពួកជំនុំនៅទីនោះឃើញយើងទៅដល់ គេយល់ថា ក្រុមជំនុំនៅទីនោះ មានតម្លៃសម្រាប់មនុស្សឯទៀត។ ដូច្នេះ បានជាការដើរសួខសុខទុក្ខពួកជំនុំមានសារៈសំខាន់សម្រាប់អ្នកទៅសួរសុខទុក្ខ ដូចជាក្រុមជំនុំនៅតាមមូលដ្ឋាន ដែលទទួលយើងផងដែរ។ សាវ័កប៉ុលទទួលការលើកទឹកចិត្តយ៉ាងខ្លាំងពីពួកជំនុំ ក៏ដូចជាពួកជំនុំ ក៏ទទួលលើកទឹកចិត្តយ៉ាងខ្លាំងពីវត្តមានរបស់លោកនៅក្នុងតំបន់របស់គេដែរ។

**អ្នកនោះមានកូនក្រមុំ៤នាក់ដែលចេះទាយទំនាយ (កិច្ចការ ២១:៩)។**

លោកភីលីព គឺជាអ្នកដែលផ្សាយដំណឹងល្អ។ អ្នកផ្សាយដំណឹងល្អ គឺជាជនដែល "នាំសេចក្តីសុខសាន្តទៅដល់អ្នកដែលស្តាប់ដំណឹងល្អ"។ នៅក្នុងខនេះ យើងឃើញថា កូនស្រីរបស់លោកភីលីព គឺជាអ្នកទទួលខុសត្រូវក្នុងកិច្ចការរបស់ក្រុមជំនុំផង។ ស្ត្រីទាំងអស់នេះ សុទ្ធតែបានទទួលអំណោយទានចេះទាយ។ នៅក្នុងសម័យដែលយើងកំពុងតែសិក្សាគម្ពីរកិច្ចការនេះ គម្ពីរសញ្ញាថ្មីមិនទាន់មានជាលាយលក្ខណ៍អក្សរនៅឡើយទេ។ ដូច្នេះ ការចេះទាយចាំបាច់ត្រូវមាននៅក្នុងក្រុមជំនុំសម័យដើម។ បន្ទាប់ពីគម្ពីរសញ្ញាថ្មីបានចងក្រងជាលាយលក្ខណ៍អក្សរហើយ បទទំនាយមិនសូវមានប្រើនៅក្នុងពួកជំនុំទៀតទេ។

**១០ លុះយើងបាននៅទីនោះជាយូរថ្ងៃ នោះមានហោរាម្នាក់ ឈ្មោះអ័ក្កាបុស គាត់ចុះពីស្រុកយូដាមក ១១ លុះមកដល់យើងហើយ គាត់ក៏យកខ្សែក្រវាត់របស់ប៉ុលមក ចងជើងចងដៃខ្លួន ប្រាប់ថា ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលដូច្នេះថា ពួកសាសន៍យូដានឹងចាប់ចងម្ចាស់ខ្សែក្រវាត់នេះបែបយ៉ាងនេះ នៅក្រុងយេរូសាឡិម**

**ហើយនឹងបញ្ជូនទៅក្នុងកណ្ដាប់ដៃនៃពួកសាសន៍ដទៃ (កិច្ចការ ២១:១០-១១)។**

ព្រះវិញ្ញាណបរិសុទ្ធបើកសម្ដែងអោយសាវ័កប៉ុលដឹងថា នៅទីក្រុងយេរូសាឡិមមានគ្រោះថ្នាក់រង់ចាំលោកនៅទីនោះ។ ព្រះជាម្ចាស់មិនចង់អោយសាវ័ប៉ុលទទួលឆ្លងកាត់គ្រោះថ្នាក់ទាំងនោះដោយភ្ញាក់ផ្អើលទេ។ ព្រះអង្គត្រូវបើកសម្ដែងអោយសាវ័កប៉ុលដឹងជាមុន ដើម្បីអោយលោកត្រៀមកាយ ចិត្ត និងវិញ្ញាណ ដើម្បីចុះចូលតាមបំណងព្រះហឫទ័យរបស់ទ្រង់។

**១២ កាលឮដូច្នោះ នោះយើង នឹងពួកអ្នកនៅទីនោះ ក៏អង្វរប៉ុលមិនឲ្យឡើងទៅឯក្រុងយេរូសាឡិមឡើយ ១៣ តែគាត់ឆ្លើយថា ហេតុអ្វីបានជាយំ ហើយធ្វើឲ្យខ្ញុំពិបាកចិត្តយ៉ាងដូច្នេះ ពីព្រោះខ្ញុំព្រមស្រេចហើយ នឹងឲ្យគេចាប់ចងខ្ញុំចុះ មិនតែប៉ុណ្ណោះសោត ថែមទាំងសុខចិត្តស្លាប់ផង នៅក្នុងក្រុងយេរូសាឡិមទៀត គឺដោយយល់ដល់ព្រះនាមព្រះអម្ចាស់យេស៊ូវ (កិច្ចការ២១:១២-១៣)។**

បណ្ឌិតលូកា គឺជាអ្នកកត់ត្រាសេចក្ដីដែលមានទាំងអម្បាលមាណ ដែលយើង

មាននៅក្នុងគម្ពីរកិច្ចការ។ លោកផ្ទាល់និងពួកជំនុំដទៃៗទៀត មិនចង់ឃើញសាវ័កប៉ុលទទួលគ្រោះថ្នាក់នៅទីក្រុងយេរូសាឡិមទេ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ បើកសម្តែងអោយសាវ័កប៉ុលដឹងហើយថា នៅទីនោះគេនឹងចាប់ចងលោក។ ប៉ុន្តែចំណែកសាវ័កប៉ុលវិញ លោកមិនមែនមានសុឆន្ទៈគ្រាន់តែអោយគេចងលោកតែប៉ុណ្ណោះទេ គឺលោកថែមទាំងចង់ស្លាប់ ដើម្បីព្រះអម្ចាស់យេស៊ូវនៅក្រុងយេរូសាឡិមទៀតផង។ ដោយសារមូលហេតុនេះហើយ បានជាសាវ័កប៉ុលសូមអង្វរដល់ពួកជំនុំកុំអោយយំ ធ្វើអោយលោកពិបាកចិត្តធ្វើអ្វី។ ការឃាត់ឃាំងរបស់ពួកជំនុំដល់សាវ័កប៉ុលគឺជាការសម្តែងទឹកចិត្តស្រឡាញ់និងគិតគូដល់សាវ័កប៉ុល ដែលជាគ្រូរបស់ខ្លួន។ ពួកជំនុំនៅទីនោះមិនមែនគ្រាន់តែស្រឡាញ់លោកប៉ុលទេ គឺគេយកចិត្តទុកដាក់ជាមួយនឹងសុខទុក្ខរបស់លោកយ៉ាងខ្លាំង។

> **នោះយើងក៏ឈប់និយាយ ដោយថា សូមតាមព្រះហឫទ័យព្រះអម្ចាស់ចុះ ពីព្រោះគាត់មិនយល់ព្រមតាមយើងទេ (កិច្ចការ ២១:១៤)។**

ខ្ញុំគិតថា បំណងព្រះហឫទ័យរបស់ព្រះ គឺចង់អោយសាវ័កប៉ុលចុះទៅសម្រេចការនោះ នៅទីក្រុងយេរូសាឡិម។

## សាវ័កប៉ុលនៅទីក្រុងយេរូសាឡិម

**[១៥] លុះផុតថ្ងៃទាំងនោះមក កាលយើងបានរៀបអីវ៉ាន់ស្រេចហើយ**
**នោះក៏ឡើងទៅឯក្រុងយេរូសាឡិម [១៦] ក៏មានសិស្សខ្លះពីសេសារា**
**ទៅជាមួយនឹងយើងដែរ បាននាំទាំងមនុស្សម្នាក់ ឈ្មោះម្នាសុន ជាសិស្សចាស់ ពីកោះគីប្រុស ដែលយើងរាល់គ្នាត្រូវស្នាក់នៅក្នុង**
**ផ្ទះគាត់ទៅផង [១៧] គ្រាដល់ក្រុងយេរូសាឡិមហើយ នោះពួកជំនុំក៏**
**ទទួលយើងដោយអំណរ (កិច្ចការ២១:១៥-១៧)។**

នៅពេលសាវ័កប៉ុលធ្វើដំណើរទៅដល់ទីក្រុងយេរូសាឡិម ពួកជំនុំនៅទីនោះបានទទួលលោកយ៉ាងកក់ក្តៅជាទីបំផុត។

**ថ្ងៃស្អែកឡើងប៉ុលក៏ចូលទៅសួរយ៉ាកុបជាមួយនឹងយើង ក្នុងកាលដែលពួកចាស់ទុំទាំងអស់ប្រជុំគ្នានៅទីនោះ (កិច្ចការ ២១:១៨)។**

គេទទួលសាវ័កប៉ុលនៅទីក្រុងយេរូសាឡិម ដូចជាទទួលស្តេចណាមួយអង្គយ៉ាងដូច្នោះដែរ។ សាវ័កប៉ុលគឺជាបេសកជនជើងចាស់សម្រាប់ក្រុមជំនុំនៅទីក្រុង

យេរូសាឡិម។ លោកបានធ្វើដំណើរជាច្រើនកន្លែង ដើម្បីផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវ។ នៅលើខ្លួនលោកមានទទួលស្នាមផ្លែរំពាត់ ដែលសម្ដែងអំពីការរងទុក្ខរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលជាអង្គសង្គ្រោះរបស់លោក។

> **១៩កាលគាត់បានជំរាបសួរដល់គេរួចហើយ នោះគាត់ថ្លែងប្រាប់ ពី**
> **អស់ទាំងការនិមួយៗ ដែលព្រះទ្រង់បានធ្វើក្នុងពួកសាសន៍ដទៃ**
> **ដោយសារគាត់ ២០គេឮដូច្នោះ ក៏សរសើរដំកើងដល់ព្រះ រួច**
> **និយាយទៅប៉ុលថា បងអើយ បងដឹងថា មានសាសន៍យូដាប៉ុន្មាន**
> **ម៉ឺនបានជឿហើយ គេសុទ្ធតែមានសេចក្ដីឧស្សាហ៍ខ្មីឃ្មាតកាន់**
> **តាមក្រិត្យវិន័យទាំងអស់គ្នា ២១ក៏បានឮនិយាយពីបងថា បង**
> **បង្រៀនដល់សាសន៍យូដាទាំងអស់ ដែលនៅជាមួយនឹងសាសន៍**
> **ដទៃ ឱ្យគេលះចោលលោកម៉ូសេចេញ ព្រមទាំងហាមប្រាមគេ**
> **កុំឱ្យកាត់ស្បែកកូន ឬប្រតិបត្តិតាមទំលាប់ពីបុរាណផង (កិច្ចការ**
> **២១: ១៩-២១)។**

សាសន៍យូដាខ្លះបាននិយាយបង្ខូចពីសាវ័កប៉ុល។ សាវ័កប៉ុលមិនបានបង្រៀនរឿងទាំងនោះដល់អ្នកដែលលោកផ្សាយដំណឹងល្អអោយគេទេ។ ប៉ុន្តែ ពួកសាសន៍យូដាគេមួលបង្កាច់ថា លោកបានបង្ហាត់បង្រៀនយ៉ាងដូច្នោះ។

ឥឡូវ យើងឈានមកដល់អត្ថបទមួយដែលមានគោលទិគួរអោយយើងមាន ការសង្ស័យចំពោះសាវ័កប៉ុល។ អ្នកបកស្រាយគម្ពីរខ្លះៗបានចោទប្រកាន់លោកប៉ុលថា លោកបានចុះទៅទីក្រុងយេរូសាឡិម ខុសអំពីបំណងព្រះហឫទ័យរបស់ព្រះ។ មិនតែប៉ុណ្ណោះ នៅទីក្រុងយេរូសាឡិមលោកថែមទាំងលាបំណន់ជាមួយនឹងសាសន៍យូដាខ្លះៗទៀតផង។ តើកិរិយាប្រព្រឹត្តរបស់លោកសាវ័កខុសជាមួយនឹងបទគម្ពីរ កំពុងដែលគ្រីស្ទបរិស័ទស្ថិតនៅក្រោមគ្រាព្រះគុណឬ?

កាលណាយើងនិយាយអំពីពួកអ្នកជឿនៅទីក្រុងយេរូសាឡិម យើងនិយាយអំពីអ្នកជឿរាប់ពាន់នាក់ ដែលជាសាសន៍យូដា។ សាសន៍យូដាដែលជឿដល់ព្រះអម្ចាស់យេស៊ូវ គេមានការប្រាកដក្នុងចិត្តថា ព្រះយេស៊ូវ គឺជាព្រះដែលយាងមកបំពេញអ្វីៗទាំងអស់ ដែលគេមិនអាចធ្វើបានតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។ ចំពោះសាសន៍យូដា ការជឿដល់ព្រះអម្ចាស់យេស៊ូវ មិនចាំបាច់លះចោលការធ្វើតាមក្រឹត្យវិន័យឡើយ។ ដ្បិតការធ្វើបុណ្យនានាតាមក្រឹត្យវិន័យរបស់លោកម៉ូសេ ជាប្រពៃណីទំនៀមទម្លាប់របស់សាសន៍យូដា។ ប៉ុន្តែ ទោះបីខ្លួនចាំបាច់ត្រូវកាន់តាមប្រពៃណីទំនៀមទម្លាប់របស់សាសន៍យូដា ពួកជំនុំសាសន៍យូដាមិនបង្ខំអោយសាសន៍ដទៃធ្វើតាមខ្លួនទេ។ ការធ្វើតាមប្រពៃណី មិនមែននាំអោយរួចពីបាបឡើយ។ សាសន៍ដទៃនិងសាសន៍យូដាអាចរួចពីបាប ដោយសារមានជំនឿជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ តែមួយមុខប៉ុណ្ណោះ។ ប៉ុន្តែ ចំណែកឯសាសន៍ដទៃវិញ យល់ថា ខ្លួនបានរួចពីបាបដោយសារព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវ ចោទប្រកាន់ដល់សាសន៍យូដាថា មិនចាំបាច់កាន់ប្រពៃណីអ្វីទៀត

ទេ។ តើការជឿដល់ព្រះអម្ចាស់យេស៊ូវ មានន័យថា យើងត្រូវបោះបង់ចោលប្រពៃណីទំនៀមទម្លាប់របស់ខ្លួនឬ? ចម្លើយដែលខ្ញុំជូនខាងក្រោមនេះ ជាចម្លើយដែលមានគោលទ្ធិចម្រូងចម្រាស។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ខ្ញុំមានការប្រាកដនៅក្នុងចិត្តរបស់ខ្ញុំថា ព្រះគម្ពីរមិនបានហាមប្រាមថា យើងដែលជឿដល់ព្រះអង្គនៅគ្រាព្រះគុណចាំបាច់ត្រូវលះបង់ទំនៀមទម្លាប់របស់យើង បើទំនៀមទម្លាប់នោះ ជាទំនៀមទម្លាប់ដែលស្របជាមួយនឹងតម្លៃដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះ។

ខ្ញុំសូមអោយឧទាហរណ៍ខ្លះ ដូចខាងក្រោមនេះ។ សាវ័កពេត្រុសមិនដែលមានចិត្តធ្វើអ្វីអោយខុសអំពីក្រឹត្យវិន័យរបស់លោកម៉ូសេទេ។ ប៉ុន្តែនៅពេលដែលលោកមកសួរសុខទុក្ខសាវ័កប៉ុលនៅទីក្រុងអាន់ទីយ៉ូក លោកបានទទួលទានអាហារនៅផ្ទះរបស់សាសន៍ដទៃ។ ចំពោះសាសន៍យូដា ការទទួលទានអាហារនៅផ្ទះសាសន៍ដទៃ រាប់ថាជាការទទួលទានសាច់ដែលបានថ្វាយទៅដល់រូបព្រះរួចហើយ។ ចំណែកសាសន៍ដទៃវិញយល់ថា សាច់ដែលថ្វាយទៅដល់រូបព្រះ គ្មានប្រយោជន៍អ្វីទេ ខ្លួនអាចទទួលទានសាច់នោះបាន ទោះបីជាបានសែនព្រេនហើយក៏ដោយ។ ប៉ុន្តែ សាសន៍ដទៃមិនព្រមទទួលទានសាច់ ដែលថ្វាយទៅដល់រូបព្រះដោយយល់ដល់បញ្ញាចិត្តរបស់សាសន៍យូដា ដែលរាប់ថាសាច់នោះជាទីស្អប់ខ្ពើម។ ហេតុដូច្នេះហើយ បានជាសាវ័កប៉ុលមានប្រសាសន៍យ៉ាងច្បាស់អំពីដំណើរប្រព្រឹត្តអ្វីមួយធ្វើអោយអ្នកដទៃធ្លាក់ពីព្រះគុណ។ លោកមានប្រសាសន៍ថា "ប៉ុន្តែ ចំណីអាហារមិនមែនជាគ្រឿងដែលនាំឱ្យព្រះរាប់អានយើងទេ ដ្បិតបើយើងបរិភោគ នោះមិនមែនមានបំណាច់អ្វី ហើយបើមិនបរិភោគទេ នោះយើង

ក៏មិនខ្វះអ្វីដែរ" (១កូរិនថូស៨:៨)។ សាវ័កប៉ុលបញ្ជាក់ថែមទៀតថា បើបុគ្គលណាម្នាក់ធ្លាប់កាន់ប្រពៃណីទំនៀមទម្លាប់អ្វីមួយ បុគ្គលនោះនៅតែបន្តកាន់ទំនៀមទម្លាប់របស់ខ្លួនបានតទៅទៀត ក្រោមព្រះគុណរបស់ព្រះជាម្ចាស់ បន្ទាប់ពីទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះរបស់ខ្លួនហើយ។ លោកបញ្ជាក់នៅក្នុងគម្ពីរ១កូរិនថូស៧:១៧-២០ថា "តែត្រូវឱ្យគ្រប់គ្នាដើរតាមដែលព្រះអម្ចាស់បានចែកឱ្យ ហើយតាមដែលព្រះបានហៅមករៀងខ្លួន ខ្ញុំក៏តាំងរបៀបយ៉ាងដូច្នេះ ក្នុងគ្រប់ទាំងពួកជំនុំដែរ បើទ្រង់បានហៅអ្នកណាដែលកាត់ស្បែកហើយ កុំឱ្យអ្នកនោះត្រឡប់ដូចជាមិនកាត់ស្បែកវិញឡើយ បើទ្រង់ហៅអ្នកណាដែលមិនបានកាត់ស្បែក កុំឱ្យអ្នកនោះកាត់ស្បែកឱ្យសោះ ព្រោះការកាត់ស្បែកមិនជាអ្វីទេ ឬដែលមិនកាត់ស្បែក នោះក៏មិនជាអ្វីដែរ តែដែលមានប្រយោជន៍ នោះគឺស្រេចនឹងកាន់តាមបញ្ញត្តរបស់ព្រះវិញ បើមនុស្សមានសណ្ឋានជាយ៉ាងណាក្នុងកាលដែលព្រះទ្រង់ហៅ នោះឱ្យប្រព្រឹត្តតាមសណ្ឋាននោះចុះ"។

សាវ័កប៉ុលប្រកាន់គោលការណ៍បែបនេះ ពីព្រោះលោកចង់អោយអ្នកដែលធ្លាប់កាន់ប្រពៃណីទំនៀមទម្លាប់នៅតែធ្វើយ៉ាងដូច្នោះ ដើម្បីអោយអ្នកដទៃទៀតអាចស្គាល់ព្រះអម្ចាស់យេស៊ូវផង។ ដូច្នេះ ហើយបានជាលោកបញ្ជាក់នៅក្នុងគម្ពីរ១កូរិនថូស៩:១៩-២៣ ថា "ដ្បិតទោះបើខ្ញុំមិនជាប់បំរើអ្នកណាសោះក៏ដោយ គង់តែខ្ញុំបានត្រឡប់ទៅជាអ្នកបំរើដល់មនុស្សទាំងអស់វិញ ដើម្បីឱ្យបានមនុស្សជាច្រើនទៅទៀត ខ្ញុំបានត្រឡប់ដូចជាសាសន៍យូដា ដល់ពួកសាសន៍យូដា ដើម្បីឱ្យបានពួកយូដា ហើយដូចជានៅក្រោមបន្ទុកក្រឹត្យវិន័យ ដល់ពួកអ្នកដែលនៅក្រោមបន្ទុកក្រឹត្យវិន័យ (តែខ្ញុំមិនមែន

នៅក្រោមបន្ទុកក្រិត្យវិន័យទេ) ដើម្បីឱ្យបានពួកអ្នកដែលនៅក្នុងបន្ទុកក្រិត្យវិន័យ ហើយដូចជាឥតក្រិត្យវិន័យដល់ពួកអ្នកដែលគ្មានក្រិត្យវិន័យ (មិនមែនថាខ្ញុំឥតក្រិត្យវិន័យរបស់ព្រះទេ គឺខ្ញុំនៅក្នុងក្រិត្យវិន័យព្រះគ្រីស្ទវិញ) ដើម្បីឱ្យបានពួកអ្នកដែលគ្មានក្រិត្យវិន័យដែរ ខ្ញុំបានត្រឡប់ដូចជាខ្សោយ ដល់ពួកអ្នកកំសោយ ដើម្បីឱ្យបានពួកកំសោយ គឺបានត្រឡប់ជាគ្រប់សណ្ឋានទាំងអស់ ដល់មនុស្សទាំងអស់ ប្រយោជន៍ឱ្យបានសង្គ្រោះដល់អ្នកខ្លះ ដោយសារសណ្ឋានទាំងនោះឯង ខ្ញុំធ្វើការទាំងនោះ ដោយយល់ដល់តែដំណឹងល្អ ដើម្បីឱ្យខ្ញុំបានចំណែកជាមួយគ្នាក្នុងដំណឹងល្អ"។ ខ្ញុំយល់ថា យើងមិនគួររិះគន់សាវ័កប៉ុល ដែលលោកចុះទៅទីក្រុងយេរូសាឡិម និងធ្វើការលាបំណន់នោះឡើយ។ សាវ័កប៉ុលជាសាសន៍យូដា ដូច្នេះ លោកលាបំណន់ដោយយល់ដល់សាសន៍យូដា។ លោកចង់អោយសាសន៍យូដាបានចូលមកជឿដល់ព្រះអម្ចាស់យេស៊ូវដែរ។ បើសាវ័កប៉ុលជាសាសន៍ដទៃវិញ ការលាបំណន់ជារឿងមួយគួរអោយយើងសួរដល់លោកដែរ។

**[២២] ដូច្នេះ តើដូចម្តេច មុខជានឹងមានគេប្រជុំគ្នាទាំងហ្វូងជាមិនខាន ដ្បិតគេនឹងឮថា បងមកដល់ហើយ [២៣] ដូច្នេះ ចូរបងធ្វើតាមពាក្យយើងវិញ ដ្បិតមានមនុស្ស៤នាក់ក្នុងពួកយើង នៅជាប់ក្នុងបំណន់នៅឡើយ [២៤] ចូរបងនាំយកគេទៅលាបំណន់ជាមួយគ្នា ហើយចេញសោហ៊ុយឱ្យគេផង ដើម្បីឱ្យគេបានកោរសក់ចេញ**

**នោះមនុស្សទាំងអស់នឹងដឹងថា សេចក្តីដែលគេឮនិយាយពីបង
នោះមិនពិតទេ គឺខ្លួនបងតែងប្រព្រឹត្តទៀងត្រង់ ហើយកាន់តាម
ក្រិត្យវិន័យដែរ ២៥ឯពួកសាសន៍ដទៃដែលជឿ នោះយើងបានផ្ញើ
សំបុត្រទៅហើយ ដោយសំរេចថា មិនចាំបាច់ឱ្យគេកាន់តាម
សេចក្តីទាំងនោះទេ ត្រូវប្រយត័តែនឹងរបស់អ្វី ដែលថ្វាយទៅរូប
ព្រះ ហើយឈាម នឹងសត្វសំឡាប់ដោយច្របាច់ក ហើយនឹង
សេចក្តីកំផិតប៉ុណ្ណោះ ២៦នោះប៉ុលក៏នាំយកអ្នកទាំងនោះទៅ លុះ
ស្អែកឡើង កាលបានញែកជាបរិសុទ្ធជាមួយនឹងគេហើយ ក៏ចូល
ទៅក្នុងព្រះវិហារ ដើម្បីប្រាប់ពីកំណត់ដែលត្រូវបានបរិសុទ្ធ
ចាំទំរាំដល់បានថ្វាយដង្វាយសំរាប់គេគ្រប់គ្នា (កិច្ចការ២១:
២២-២៦)។**

លោកបញ្ជាក់ប្រាប់ដល់ពួកជំនុំដែលជាសាសន៍យូដា រាប់ពាន់នៅទីក្រុងយេរូសាឡិមថា នៅពេលដែលសាសន៍យូដាត្រឡប់មកជាគ្រីស្ទបរិស័ទ សាសន៍យូដានៅតែជាសាសន៍យូដា។ សាសន៍ដទៃដែលត្រឡប់មកជាគ្រីស្ទបរិស័ទនៅតែជាសាសន៍ដទៃ។ ការជឿដល់ព្រះអម្ចាស់យេស៊ូវ មិនទាមទារអោយយើងដូរស្បែក ដូរពណ៌សម្បុរ ដូរប្រពៃណីទំនៀមទម្លាប់របស់យើងនោះឡើយ។ ករណីនេះ អនុវត្តបានចំពោះជាជនជាតិខ្មែរ។ បន្ទាប់ពីយើងជឿដល់ព្រះអម្ចាស់យេស៊ូវហើយ យើងមិនត្រូវបំភ្លេចចោល

ប្រពៃណីទំនៀមទម្លាប់ណាដែលល្អៗរបស់យើងនោះទេ។ យើងត្រូវបន្តរក្សាប្រពៃណីទំនៀមទម្លាប់របស់យើង ដើម្បីអោយអ្នកផងទាំងពួងបានស្គាល់ព្រះអម្ចាស់យេស៊ូវតាមរយៈទំនៀមទម្លាប់របស់យើងនោះផងដែរ។

លោកអ្នកបងប្អូនអើយ លោកអ្នកមិនចាំបាច់ធ្វើការបែរបន់អ្វីទេ។ ប៉ុន្តែបើលោកអ្នកចង់បែរបន់ រឿងនេះជាសិទ្ធិរបស់លោកអ្នកបងប្អូន។ ម្យ៉ាងទៀត លោកអ្នកមិនចាំបាច់កោរសក់ដើម្បីធ្វើជាអ្នកជឿដល់ព្រះអម្ចាស់ទេ។ ប៉ុន្តែបើលោកអ្នកបងប្អូនចង់កោរសក់ រឿងនោះជារឿងរបស់លោកអ្នកបងប្អូនផ្ទាល់ជាមួយនឹងព្រះជាម្ចាស់។ ម្យ៉ាងវិញទៀត លោកអ្នកបងប្អូនមិនចាំបាច់បែរបន់ជាមួយនឹងព្រះទុកសក់វែង សម្រាប់បម្រើព្រះអង្គទេ ប៉ុន្តែបើលោកអ្នកចង់ទុកសក់វែងជារឿងរបស់លោកអ្នកបងប្អូនផ្ទាល់។ នៅក្រោយគ្រាព្រះគុណ យើងអាចមានសិទ្ធិធ្វើអ្វីដែលយើងយល់ថា ជាផលប្រយោជន៍សម្រាប់ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ។ សូមលោកអ្នកយល់ថា យើងទាំងអស់គ្នាមិនមែនរួចពីបាបដោយសារការប្រព្រឹត្តទេ គឺយើងបានរួចពីបាបដោយសារព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់សុគតនៅលើឈើឆ្កាងទាំងរស់ពីសុគតឡើងវិញសម្រាប់យើងគ្រប់គ្នាផង។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"